# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




**Asian InternationalJustice Initiative(AIJI), a project of East-West Center and UC Berkeley War Crimes Studies Center**

*ខ្ញុំគ្រាន់តែចង់ជម្រាបជូនថា ខាងការពារក្តីគាំទ្រអំណះអំណាងរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនធ្លាប់ធ្វើពីមុននោះទេ ហើយពួកយើងគាំទ្រអំពីឋានៈដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងសាក្សី ខុសគ្នា។*

- **លោកស្រី អង់តា ហ្គីសសេ** *(Ms. Anta Guissé)*

## ផ្នែកទី ១៖ ទិដ្ឋភាពទូទៅ

កាលពីថ្ងៃអង្គារនាសប្តាហ៍នេះ អង្គជំនុំជម្រះបានរៀបចំកិច្ចប្រជុំពិភាក្សាពីការគ្រប់គ្រងសវនាការ ដោយមានបំណងលើកឡើងនូវបញ្ហាប្រឈមសំខាន់ៗមួយចំនួន នៅចំពោះមុខអង្គជំនុំជម្រះ និងដើម្បីរៀបចំកាលវិភាគចុងក្រោយ។ បន្ទាប់ពីបានស្តាប់សវនាការនៃការដាក់សំណើដោយផ្ទាល់មាត់រួចហើយ អង្គជំនុំជម្រះបានបដិសេធនូវសំណើរបស់ភាគីសហព្រះរាជអាជ្ញា ក្នុងការកោះហៅសាក្សីបន្ថែម ដើម្បីផ្តល់សក្ខីកម្មពីឧក្រិដ្ឋកម្មនៅទួលពោធិ៍ជ្រៃ និងការកោះហៅដើមបណ្តឹងរដ្ឋប្បវេណី **ស សារិន** សាជាថ្មីម្តងទៀត។ សំណើរបស់ក្រុមមេធាវីការពារក្តីឲ្យលោក **នួន ជា** ក្នុងការកោះហៅសាក្សី **រ៉ប់ លឹមគិន** *(Mr. Rob Lemkin)* ក៏ត្រូវបានបដិសេធចោលផងដែរ។ ជាកិច្ចបញ្ចប់នៃសវនាការ អង្គជំនុំជម្រះបានណែនាំអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ឲ្យរៀបចំនូវរបាយការណ៍ជាលក្ខណៈផ្លូវការមួយ រៀបរាប់អំពីរបៀបដែលសាក្សី **នូ មោក** បានកាន់កាប់រូបថត និងកំណត់ហេតុនៃកិច្ចសម្ភាសន៍របស់លោក **ប៊ែន ឃៀរនិន** *(Mr. Ben Kiernan)* មុនពេលនៃការមកផ្តល់សក្ខីកម្មរបស់គាត់នៅចំពោះមុខអង្គជំនុំជម្រះ។ ពាក់ព័ន្ធទៅនឹងសំណើរបស់ភាគីសហព្រះរាជអាជ្ញា ក្នុងការស្នើសុំឲ្យអង្គជំនុំជម្រះដាក់ចេញនូវសេចក្តីសម្រេច ប្រឆាំងនឹងសហជនជាប់ចោទក្នុងការជ្រើសរើសអនុវត្តសិទ្ធិរក្សាភាពស្ងៀមស្ងាត់របស់ពួកគាត់។ អង្គជំនុំជម្រះបានសម្រេចថា បញ្ហានេះនឹងត្រូវដោះស្រាយ នៅក្នុងអំឡុងពេលនៃការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល។[1]

លោកប្រធានចៅក្រម និល ណុន បានប្រកាសផ្អាកកិច្ចដំណើរការនីតិវិធី រហូតដល់ថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៣ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូង បានកំណត់កាលវិភាគសម្រាប់ស្តាប់សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលពីគ្រប់ភាគីទាំងអស់។[2] កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ អង្គជំនុំជម្រះតុលាការកំពូល បានចេញនូវសេចក្តីសង្ខេបមួយ ពីមូលហេតុគាំទ្រលើការសម្រេចច្រានចោលការជំទាស់ ប្រឆាំងនឹងដីកាបំបែកសំណុំរឿងរបស់អង្គជំនុំជម្រះសាលាដំបូង ពីសំណាក់ភាគីសហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តីឲ្យលោក នួន ជា។ ដោយសារតែអង្គជំនុំជម្រះតុលាការកំពូល បានបដិសេធចោលនូវការស្នើសុំពង្រីកវិសាលភាពនៃសំណុំរឿង០០២ វគ្គទី១ នេះ ហេតុដូច្នេះហើយទើប កិច្ចប្រជុំពិភាក្សាពីការគ្រប់គ្រងសវនាការ បានកំណត់ពីការបញ្ចប់សវនាការលើភស្តុតាងក្នុងករណីនៃសំណុំរឿង ០០២ វគ្គទី១ នេះ។[3]

## ផ្នែកទី ២ ៖ បញ្ហាច្បាប់ និងនីតិវិធី

កិច្ចប្រជុំពិភាក្សាពីការគ្រប់គ្រងសវនាការ បានលើកឡើងនូវបញ្ហាច្បាប់ និងនីតិវិធីជាច្រើន រួមមាន៖ សំណើពីភាគីនានា ក្នុងការកោះហៅសាក្សីបន្ថែម និងការកោះហៅដើមបណ្តឹងរដ្ឋប្បវេណីមួយរូប សាជាថ្មីម្តងទៀត មុននឹងបញ្ចប់សវនាការលើភស្តុតាង។ អង្គជំនុំជម្រះ បានសម្រេចទៅលើបញ្ហាភាគច្រើន ដែលបានលើកឡើង ជាមួយនឹងការលើកលែងដែលថា តើប្រតិចារឹកនៃសំណុំរឿង០០១ អាចនឹងត្រូវដាក់បញ្ចូលជាភស្តុតាងសម្រាប់សំណុំរឿង (០០២) មួយនេះដែរឬទេ? ហើយតើត្រូវរៀបចំចាត់ថ្នាក់ឯកសារលេខ E/3 ដោយរបៀបណា? អង្គជំនុំជម្រះ ក៏បានពន្យារពេល ក្នុងការចេញនូវសេចក្តីសម្រេចចុងក្រោយទៅលើថា តើគួរចេញសេចក្តីសម្រេចប្រឆាំងទៅនឹងសហជនជាប់ចោទ និងស្នើសុំព័ត៌មានបន្ថែមពីសំណាក់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ពាក់ព័ន្ធនឹងការចោទប្រកាន់ដែលថា ការផ្តល់សក្ខីកម្មរបស់សាក្សី **នូ មោក** គឺមិនមានភាពស្មោះត្រង់ទេ។

### ក. សំណើរបស់ភាគីសហព្រះរាជអាជ្ញា ក្នុងការកោះហៅសាក្សីអំពីទួលពោធិ៍ជ្រៃបន្ថែម

អង្គជំនុំជម្រះ បានចាប់ផ្តើមពិភាក្សាអំពីបញ្ហាប្រឈមសំខាន់ៗ មួយចំនួន ដែលនៅសេសសល់នៅចំពោះមុខតុលាការទាំងមូល ដោយដំបូងឡើយ អង្គជំនុំជម្រះបានលើកយកនូវសំណើរបស់ភាគីសហព្រះរាជអាជ្ញា ក្នុងការកោះហៅសាក្សីចំនួនប្រាំនាក់បន្ថែមទៀត ដើម្បីមកផ្តល់សក្ខីកម្មអំពីឧក្រិដ្ឋកម្មនៅទួលពោធិ៍ជ្រៃ។ បន្ទាប់ពីបានស្តាប់អំណះអំណាងពីគ្រប់ភាគីទាំងអស់រួចហើយ អង្គជំនុំជម្រះ បានច្រានចោលនូវសំណើទាំងនោះ ដោយផ្អែកលើសម្អាងថា សក្ខីកម្មបន្ថែមទាំងនោះ អាចនឹងមានភាពច្រំដែល។ មេធាវីជាតិនាំមុខដើមបណ្តឹងរដ្ឋប្បវេណី **ពេជ អង្គ** បានគាំទ្រនូវសំណើរបស់ភាគីសហព្រះរាជអាជ្ញា ដោយសារមូលហេតុថា សាក្សីបន្ថែមអាចមានលទ្ធភាពក្នុងការបំភ្លឺ អំពីរចនាសម្ព័ន្ធដឹកនាំរបស់ខ្មែរក្រហម និងឧក្រិដ្ឋកម្មដែលចោទប្រកាន់ថា បានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃ។ មេធាវីអន្តរជាតិការពារក្តីឲ្យលោក **នួន ជា** គឺលោក **វិចទ័រ កូប៉េ** *(Mr. Victor KOPPE)* ក៏បានគាំទ្រសំណើរបស់ភាគីសហព្រះរាជអាជ្ញាផងដែរ ជាគោលការណ៍ គឺដើម្បីទាញការស្នើសុំថា អ្នកផលិតខ្សែ

ភាពយន្ត "មួយថ្ងៃនៅទួលពោធិ៍ជ្រៃ" គឺលោក **រ៉ប់ លឹមគិន** ក៏គួរតែត្រូវបានកោះហៅឲ្យ មកផ្តល់សក្ខីកម្មផងដែរ។ មេធាវីអន្តរជាតិការពារក្តីឲ្យលោក **ខៀវ សំផន** គឺលោកស្រី **អង់តា ហ្គីសសេ** ក៏បានគូសបញ្ជាក់ផងដែរថា អង្គជំនុំជម្រះ គួរតែបិទបញ្ចប់កិច្ចដំណើរការនីតិវិធី នៅដំណាក់កាលណាមួយ ហើយបានបន្ថែមថា "ប្រសិនបើ ភស្តុតាងមិនគ្រប់គ្រាន់នោះ យើងគ្រាន់តែទាញសេចក្តីសន្និដ្ឋានដែរទៅថា មិនមានព័ត៌មានគ្រប់គ្រាន់ តែប៉ុណ្ណឹងទៅបានហើយ"។ សហព្រះរាជអាជ្ញា **ឌេល លីសាក់** *(Mr. Dale LYSAK)* បានគូសបង្ហាញពីសារសំខាន់របស់សាក្សីជាច្រើនរូប ដោយបានបន្ថែមថា សាក្សីទាំងអស់នោះ អាចផ្តល់នូវព័ត៌មានជាក់លាក់សំខាន់ៗ មួយចំនួននៅទួលពោធិ៍ជ្រៃ។ ជាកិច្ចឆ្លើយតបទៅនឹងសំណើរបស់លោកមេធាវី **គូប៉េ** ក្នុងការកោះហៅសាក្សី **រ៉ប់ លឹមគិន** សហព្រះរាជអាជ្ញា **ឌេល លីសាក់** បានបញ្ជាក់ថា អ្នកផលិតខ្សែភាពយន្តរូបនេះ ហាក់បីដូចជា "មិនបានយល់ច្បាស់អំពីខ្សែភាពយន្តរបស់ខ្លួននោះទេ។"

## ខ. សំណើរបស់ភាគីសហព្រះរាជអាជ្ញា ក្នុងការកោះហៅដើមបណ្តឹងរដ្ឋប្បវេណី ស សារិន សាជាថ្មីម្តងទៀត

កាលពីព្រឹកថ្ងៃអង្គារ ភាគីមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី បានដឹងថា ពួកគេមានការព្រមព្រៀងខ្លះៗ ជាមួយនឹងក្រុមមេធាវីការពារក្តី ពាក់ព័ន្ធទៅនឹងសំណើមួយរបស់ភាគីសហព្រះរាជអាជ្ញា ក្នុងការកោះហៅដើមបណ្តឹងរដ្ឋប្បវេណី **ស សារិន** សាជាថ្មីម្តងទៀត។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ធ្លាប់បានកោះហៅឲ្យមកផ្តល់សក្ខីកម្មម្តងរួចមកហើយ គឺកាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៣ ប៉ុន្តែត្រូវបានលាលែង ដោយអង្គជំនុំជម្រះសាលាដំបូង បន្ទាប់ពីគាត់បានបង្ហាញនូវភាពភ័យខ្លាចចំពោះអាយុជីវិតរបស់គាត់ និងបានបដិសេធមិនព្រមផ្តល់សក្ខីកម្ម លុះត្រាតែផ្តល់អង្គរក្សផ្ទាល់ខ្លួនសម្រាប់គាត់ ឬបញ្ជូនគាត់ទៅប្រទេសលោកខាងលិច។ តុលាការបានឆ្លើយតបនឹងសំណើនេះថា តុលាការនេះមិនមានយុត្តាធិការ ក្នុងការផ្តល់វិធានការការពារណាមួយ ដូចដែលគាត់បានស្នើសុំនោះឡើយ ហេតុដូច្នេះហើយ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ក៏ត្រូវបានលាលែងទៅ។ កាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៣ ការិយាល័យសហព្រះរាជអាជ្ញា ក៏បានដាក់សំណើមួយទៀតទៅកាន់អង្គជំនុំជម្រះ ដើម្បីឲ្យអង្គជំនុំជម្រះធ្វើការពិចារណាសាជាថ្មីម្តងទៀត ទៅលើការសម្រេចមិនកោះហៅដើមបណ្តឹងរដ្ឋប្បវេណីលោក **ស សារិន** ដោយការប្រើប្រាស់សិទ្ធិអំណាចរបស់តុលាការ ក្នុងការបង្ខំឲ្យសាក្សីផ្តល់សក្ខីកម្ម ដែលអនុលោមតាមវិធានផ្ទៃក្នុង វិធាន៣៥។[4] នៅពេលរសៀល អង្គជំនុំជម្រះ បានចេញនូវសេចក្តីសម្រេចចុងក្រោយមួយឆ្លើយតបទៅនឹងការស្នើសុំរបស់ភាគីសហព្រះរាជអាជ្ញា ដោយយោងទៅលើហេតុផលថា មិនមានភស្តុតាងថ្មីណាមួយ ត្រូវបានលើកឡើង ដើម្បីផ្លាស់ប្តូរសេចក្តីសម្រេចដំបូងរបស់អង្គជំនុំជម្រះនោះទេ។[5] ទោះជាយ៉ាងណាមុននឹងធ្វើការសម្រេចចុងក្រោយនេះ អង្គជំនុំជម្រះក៏បានអនុញ្ញាតឲ្យភាគីទាំងអស់ បង្ហាញនូវទឡ្ហីករណ៍របស់ពួកគេរៀងៗខ្លួន ពាក់ព័ន្ធទៅនឹងសំណើទាំងនេះផងដែរ។

មេធាវីដើមបណ្តឹងរដ្ឋប្បវេណី **វ៉ែន ពៅ** បានគូសបញ្ជាក់ពីភាពខុសគ្នារវាង ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីថា វិធានផ្ទៃក្នុង វិធាន៣៥ គឺអាចអនុវត្តបានទៅលើសាក្សីតែប៉ុណ្ណោះ។ មេធាវីអន្តរជាតិនាំមុខដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី **ស៊ីម៉ុនណូហ្វត** *(Ms. SIMONNEAU-FORT)* បានអះអាងថា វិធានផ្ទៃក្នុង វិធាន ៤១(៥) មិនបានបញ្ជាក់ពីកាតព្វកិច្ចឲ្យបង្ហាញខ្លួនទេ ហើយក៏បានថ្លែងទៀតថា មានតែសាក្សីប៉ុណ្ណោះ ដែលមានកាតព្វកិច្ចបង្ហាញខ្លួន នៅចំពោះមុខអង្គជំនុំជម្រះ។[6] ភាគីក្រុមមេធាវីការពារក្តី ក៏បានគាំទ្រនូវការវែកញែកពីភាពខុសគ្នារវាងសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ពីសំណាក់ភាគីមេធាវីដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។ លោកស្រី **អង់តាហ្គីសសេ** ក៏បានរក្សានូវគោលជំហរផងដែរថា ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូប គឺមិនមានអ្វីអាចមកបង្ខិតបង្ខំលោក **ស សារិន** ឲ្យមកផ្តល់សក្ខីកម្មបានទេ ប្រសិនបើគាត់មិនចង់ធ្វើទេនោះ។ ជាកិច្ចបកស្រាយបន្ថែមទៅលើឆន្ទៈរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការផ្តល់សក្ខីកម្ម លោកមេធាវី **ពេជ អង្គ** បានជម្រាបទៅតុលាការថា លោក **ស សារិន** មានបំណងចង់ផ្តល់ព័ត៌មាន ប៉ុន្តែគាត់មានភាពភ័យខ្លាចក្នុងការផ្តល់សក្ខីកម្ម ប្រសិនបើតុលាការមិនបានផ្តល់វិធានការការពារ ដូចអ្វីដែលគាត់បានស្នើសុំ។ បន្ទាប់ពីបានដឹងថា ដើមបណ្តឹងរដ្ឋប្បវេណីមានវត្តមាននៅក្នុងសាលសវនាការសាធារណៈ ដើម្បីតាមដានកិច្ចដំណើរការនីតិវិធី ចៅក្រម **ហ្សង់ម៉ាកឡាវ៉ែន៍** *(Judge Jean-Marc LAVERGNE)* ក៏បានស្នើសុំឲ្យលោក **ស សារិន** ចាប់ផ្តើមធ្វើការឆ្លើយតបទៅនឹងសំណួរមួយចំនួន។ បន្ទាប់ពីបានបញ្ជាក់ម្តងហើយម្តងទៀតថា តុលាការមិនអាចផ្តល់វិធានការការពារណាមួយ ដែលគាត់បានស្នើសុំនោះរួចហើយ ចៅក្រម **ឡាវ៉ែន៍** ក៏បានសួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណីទៀតថា តើគាត់មានបំណងក្នុងការផ្តល់សក្ខីកម្មដែរឬទេ។ មួយសន្ទុះក្រោយមក លោក **ស សារិន** បានប្រាប់តុលាការថា សក្ខីកម្មរបស់គាត់ អាចជះឥទ្ធិពលប៉ះពាល់ដល់ប្រទេសជិតខាង ហើយគាត់នៅតែមិនមានឆន្ទៈ ក្នុងការផ្តល់សក្ខីកម្ម ដរាបណាមិនមានការធានាណាមួយ ពីសុវត្ថិភាពផ្ទាល់ខ្លួនរបស់គាត់។ ទោះជាយ៉ាងណាក្តី ភាគីសហព្រះរាជអាជ្ញានៅតែបន្តរក្សានូវសំណើរបស់ពួកគេ នៅចំពោះមុខអង្គជំនុំជម្រះ ដោយសម្អាងទៅលើទឡ្ហីករណ៍ថា អតីតកម្មាភិបាលខ្មែរក្រហម **ស សារិន** មិនមែនគ្រាន់តែជាសាក្សីធម្មតាម្នាក់ទេ។ លើសពីនេះទៀត ភាគីសហព្រះរាជអាជ្ញាបានបន្ថែមទៀតថា ពាក្យ "កោះហៅ" នៅក្នុងវិធានផ្ទៃក្នុង វិធាន៤១ គឺគួរតែអនុវត្តចំពោះជនទូទៅគ្រប់រូប រួមបញ្ចូលទាំង ដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។[7]

## គ. សំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំសេចក្តីសម្រេចប្រឆាំងនឹងសហជនជាប់ចោទ

ក្នុងអំឡុងពេលនៃកិច្ចប្រជុំពិភាក្សាពីការគ្រប់គ្រងសវនាការ សហព្រះរាជអាជ្ញា **ខេល លីសាក់** ត្រូវបានស្នើសុំឲ្យធ្វើបទបង្ហាញពីទឡ្ហីករណ៍ ពាក់ព័ន្ធទៅនឹងសំណើរបស់ភាគីសហព្រះរាជអាជ្ញា ទៅកាន់អង្គជំនុំជម្រះ ក្នុងការស្នើសុំសេចក្តីសម្រេចប្រឆាំងនឹងជនជាប់ចោទ **នួន ជា** និងជនជាប់ចោទ **ខៀវ សំផន** ដោយផ្អែកទៅលើមូលដ្ឋាន ដែលជនជាប់ចោទទាំងពីររូប បានបដិសេធមិនឆ្លើយតបទៅនឹងសំណួរ កាលពីពេលថ្មីៗនេះ។ ជាកិច្ចបន្ថែមទៅលើការស្នើសុំនោះ សហព្រះរាជអាជ្ញា **លីសាក់** បានគូសបញ្ជាក់ថា ដើម្បីឃាតចេញពីការរក្សា

ភាពស៊ៀមស្ងាត់ ដំបូងឡើយ សហជនជាប់ចោទត្រូវតែដឹងអំពីប្រធានបទ ដែលពួកគេអាចនឹងត្រូវបានគេចោទសួរ។ ហេតុដូច្នេះហើយ ការិយាល័យសហព្រះរាជអាជ្ញា បានស្នើសុំពេលវេលាពីរម៉ោង ដើម្បីតាំងសំណួរទៅកាន់សហជនជាប់ចោទ។ ជាការឆ្លើយតបក្នុងនាមជាតំណាងឲ្យក្រុមមេធាវីការពារក្តីឲ្យលោក **ខៀវ សំផន** លោកស្រីមេធាវី **អង់តា ហ្គីសសេ** បានរក្សានូវគោលជំហរថា សំណើរបស់ភាគីសហព្រះរាជអាជ្ញា ពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចប្រឆាំងនឹងសហជនជាប់ចោទ គឺជាបញ្ហាមួយនៃការធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោល។ ជាការយល់ស្របជាមួយនឹងការលើកឡើងរបស់មេធាវីការពារក្តី អង្គជំនុំជម្រះបានជូនដំណឹងទៅភាគីសហព្រះរាជអាជ្ញាថា ពួកគេអាចលើកអំណះអំណាងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង អំពីសេចក្តីសម្រេចប្រឆាំងនឹងសហជនជាប់ចោទ នៅក្នុងអំឡុងពេលនៃការធ្វើសេចក្តីសន្និដ្ឋានសង្ខេបរបស់ពួកគេបាន ហើយអង្គជំនុំជម្រះបានបន្ថែមទៀតថា វាមិនមានការចាំបាច់ទេសម្រាប់សហជនជាប់ចោទ ក្នុងការតតាំងដោយផ្ទាល់ជាមួយនឹងប្រធានបទ ដែលភាគីសហព្រះរាជអាជ្ញាមានបំណងនឹងធ្វើការចោទសួរនោះ។

## ឃ. សំណើបញ្ជាក់អំណះអំណាងចំពោះឯកសារ ដែលទទួលយកជាភស្តុតាង

ក្នុងអំឡុងពេលនៃកិច្ចប្រជុំពិភាក្សាពីការគ្រប់គ្រងសវនាការ សំណើជាច្រើនពីគ្រប់ភាគីទាំងអស់ ដាក់ជូនទៅកាន់អង្គជំនុំជម្រះ ដើម្បីអះអាងថា តើឯកសារណាខ្លះដែលត្រូវបានទទួលស្គាល់ និងដាក់ចូលជាភស្តុតាង ហើយត្រូវបានធានាដោយអង្គជំនុំជម្រះថា ឯកសារទាំងនោះនឹងត្រូវបានសម្រេចដោយអង្គហេតុណាមួយ នាថ្ងៃអនាគត។ ជាក់ស្តែង គឺនៅពេលដែលភាគីនានាយល់ឃើញថា ការសម្រេចសេចក្តី គឺមិនមានភាពច្បាស់លាស់។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះបានជម្រាបដល់ភាគីទាំងអស់ថា ពួកគេនឹងត្រូវបានអនុញ្ញាតឲ្យបន្ថែមការឆ្លើយតបចំនួន ២៥ទំព័របន្ថែមទៀត។ ភាគីការិយាល័យសហព្រះរាជអាជ្ញា បានជម្រាបអង្គជំនុំជម្រះថា ដើម្បីរៀបចំសេចក្តីសន្និដ្ឋានបញ្ចប់ ពួកគេបានទាមទារឲ្យមានការសម្រេចលើប្រធានបទទូទៅមួយចំនួន រួមមាន តើសេចក្តីថ្លែងការណ៍ជាច្រើនរបស់សាក្សី ត្រូវបានទទួលស្គាល់ជាភស្តុតាង ដែរឬទេ។ ទាំងក្រុមមេធាវីការពារក្តី និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានលើកឡើងនូវការគាំទ្ររបស់ពួកគេចំពោះសំណើនេះ ហើយថែមទាំងបានស្នើសុំទៅកាន់អង្គជំនុំជម្រះ ឲ្យធ្វើការសម្រេចឲ្យបានឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន។ លោកស្រី **អង់តា ហ្គីសសេ** បានបន្ថែមថា ក្រុមការពារក្តីរបស់លោក **ខៀវ សំផន** បានកត់សម្គាល់ឃើញនូវបញ្ហានៃការបកប្រែភាសាមួយចំនួន នៅក្នុងសក្ខីកម្មជាច្រើន ហើយលោកស្រីបានស្នើសុំពេលវេលាចំនួនពីរសប្តាហ៍បន្ថែមទៀត ដើម្បីធ្វើការត្រួតពិនិត្យលើឯកសារទាំងនោះ។ អង្គជំនុំជម្រះ មិនបានសម្រេចលើបញ្ហានេះទេ។

## ង. សំណើកោះហៅលោក រ៉ប់ លឹមគិន និងសាក្សីបន្ថែម

ក្រុមមេធាវីការពារក្តីរបស់លោក នួន ជា ក៏ត្រូវបានស្នើសុំឲ្យបង្ហាញអំណះអំណាង ដោយផ្ទាល់មាត់ផងដែរ ដើម្បីគាំទ្រនូវសំណើសុំកោះហៅលោក **រ៉ប់ លឹមគិន** និងសាក្សីចំនួន ១១០នាក់ បន្ថែមទៀត ដែលពាក់

ព័ន្ធទៅនឹងការផ្តល់សក្ខីកម្មអំពីគោលនយោបាយ នៃការកំណត់ទាហាន និងមន្ត្រី **លន់ នល់**។ អង្គជំនុំជម្រះបានច្រានចោលនូវសំណើនោះ ដោយបានសម្រេចថា ក្រុមមេធាវីការពារក្តីបានបរាជ័យ ក្នុងការផ្តល់មូលហេតុដ៏សមរម្យមួយ ដូចដែលបានទាមទារនៅក្នុងវិធានផ្ទៃក្នុង វិធាន៨៧(៤) ហើយអង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីទាំងអស់ថា ការសម្រេចនេះនឹងត្រូវបកស្រាយលម្អិតបន្ថែមទៀត នៅក្នុងសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ។[8] លោកមេធាវី **កូប៉េ** បានលើកឡើងអំពីបញ្ហានេះជាលើកដំបូង កាលពីសប្តាហ៍មុន បន្ទាប់ពីបានទទួលអ៊ីម៉ែលពីលោក **រ៉ប់ លឹមតិន** ដែលអ៊ីម៉ែលនោះបានសរសេរថា អ្នកដឹកនាំខ្សែភាពយន្ត មានព័ត៌មានទាក់ទងទៅនឹងតួនាទីរបស់លោក **នួន ជា** ស្តីពីការចោទប្រកាន់ថា បានសម្លាប់ទាហាន **លន់ នល់** នៅទួលពោធិ៍ជ្រៃ។[9] លោកមេធាវី **កូប៉េ** បានលើកទឡ្ហីករណ៍ថា សក្ខីកម្មរបស់សាក្សីជាច្រើនរូប របស់ភាគីសហព្រះរាជអាជ្ញា ទាក់ទងទៅនឹងការសម្លាប់ គឺភាគច្រើនបានមកពីពាក្យចចាមអារ៉ាម ហើយក៏បានបង្ហាញថា មិនគួរឲ្យជឿជាក់ផងដែរ នៅក្នុងអំឡុងពេលនៃការសាកសួរដេញដោល។ ហេតុដូច្នេះហើយ លោកមេធាវី **កូប៉េ** បានបន្ថែមទៀតថា ប្រសិនបើ អង្គជំនុំជម្រះសម្រេចទទួលយកសេចក្តីថ្លែងការណ៍ចំនួន ១១០បន្ថែមទៀត ប្រការនេះ ធ្វើឲ្យភាគីក្រុមមេធាវីការពារក្តី មានសិទ្ធិដោយ "ស្វ័យប្រវត្តិ" ក្នុងការសាកសួរសំណួរឆ្លងទៅកាន់សាក្សីទាំងអស់នោះ។ ជាកិច្ចឆ្លើយតបនឹងការលើកឡើងរបស់ភាគីមេធាវីការពារក្តីឲ្យជនជាប់ចោទ សហព្រះរាជអាជ្ញា **ឌេល លីសាក់** បានលើកឡើងថា លោកមេធាវី **កូប៉េ** បាន "បន្ទោសបង្អាក់អត្តចរិត" នៃការផ្តល់សក្ខីកម្មរបស់សាក្សី ហើយមានបំណងលុបបំបាត់ចោលសក្ខីកម្មរបស់លោក **រ៉ុកហ្វ** *(Mr. Al Rockoff)* លោក **ឌុច** *(Mr. Duch)* លោក **ហ្វីលីព ស្សត** *(Mr. Philip Short)* និងលោក **ស៊ីដនី ស្តេនប៊ឺក** *(Mr. Sydney Schanberg)*។ លោកស្រីមេធាវីអន្តរជាតិនាំមុខដើមបណ្តឹងរដ្ឋប្បវេណី **អេលីហ្សាបេត ស៊ីម៉ុនណូហ្វត** បានគាំទ្រនូវជំហររបស់ភាគីសហព្រះរាជអាជ្ញា ហើយបានបន្ថែមថា វាមិនមានភាពចាំបាច់ទេ សម្រាប់ការកោះហៅសាក្សីបន្ថែមទៀតនោះ ពីព្រោះតុលាការ អាចយោងទៅលើការស៊ើបអង្កេតមុនអង្គបុរេជំនុំជម្រះ និងធ្វើការសាកល្បងពីភាពគួរជឿជាក់របស់សាក្សីដែលធ្លាប់បានផ្តល់សក្ខីកម្មពីបញ្ហានេះ។

## ច. សំណើសុំព័ត៌មានទំនាក់ទំនងរបស់លោក នូ មោក ជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ

បញ្ហាទាក់ទងនឹងរបៀបដែលសាក្សី **នូ មោក** បានរក្សាទុកនូវរូបថត និងកំណត់ត្រានៃកិច្ចសម្ភាសន៍របស់លោក **ប៊ែន ឃៀរនិន** មុនពេលមកផ្តល់សក្ខីកម្មនៅចំពោះអង្គជំនុំជម្រះ កាលពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៣ ក៏ត្រូវបានលើកយកមកពិភាក្សាដេញដោលផងដែរ នៅក្នុងអំឡុងពេលកិច្ចប្រជុំពិភាក្សាពីការគ្រប់គ្រងសវនាការ។[10] បន្ទាប់ពីបានស្តាប់អំណះអំណាងពីសំណាក់ភាគីទាំងអស់រួចហើយ អង្គជំនុំជម្រះបានបដិសេធពីការស៊ើបអង្កេតលើបញ្ហានេះ ប៉ុន្តែអង្គជំនុំជម្រះបានណែនាំឲ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញរៀបចំរបាយការណ៍ផ្លូវការមួយ ដើម្បីធ្វើបទបង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ នៅក្នុងរយៈពេលពីរសប្តាហ៍។

លោកស្រីមេធាវី **អង់តា ហ្គីសសេ** បានអះអាងថា ការស៊ើបអង្កេត គឺពិតជាមានសារសំខាន់ណាស់ ដើម្បីឲ្យដឹងច្បាស់ថា តើនៅពេលណាដែលការផ្តល់សក្ខីកម្មរបស់សាក្សី **នូ មោក** "មិនបរិសុទ្ធ" ហើយតើគាត់ត្រូវបានគេណែនាំ ឬក៏ប្រាប់ក្នុងវិធីសាស្រ្តណាមួយ ដែរឬយ៉ាងណានេះ។ សហព្រះរាជអាជ្ញា **លីសាក់** បានលើកឡើងនូវអំណះអំណាងថា មិនមានការស៊ើបអង្កេតណាមួយ គឺចាំបាច់តទៅទៀតទេ ដោយសារតែអង្គភាពគាំពារសាក្សី និងអ្នកជំនាញ បានផ្តល់ត្រឹមតែរូបថតទៅឲ្យលោក **នូ មោក** ដើម្បីធានាថា ពួកគេបានរកឃើញសាក្សីដ៏ត្រឹមត្រូវហើយ។ លើសពីនេះទៅទៀត គាត់បានលើកឡើងថា វាគឺពិតជាត្រឹមត្រូវណាស់ ដែលលោក **នូ មោក** ត្រូវបានគេផ្តល់ឱកាសមួយ ក្នុងការត្រួតពិនិត្យឡើងវិញនូវបទសម្ភាសន៍របស់គាត់។

## ឆ. សេចក្តីសម្រេចរបស់តុលាការកំពូលលើបណ្តឹងឧទ្ធរណ៍ របស់សហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តីឲ្យលោក នួន ជា ចំពោះសេចក្តីសម្រេចលើដីកាបំបែកសំណុំរឿងលើកទីពីររបស់តុលាការដំបូង

កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ តុលាការកំពូលបានចេញសេចក្តីសង្ខេបពីហេតុផល ដើម្បីគាំទ្រសេចក្តីសម្រេចរបស់ខ្លួន ក្នុងការច្រានចោលនូវបណ្តឹងឧទ្ធរណ៍ភ្លាមៗ ពីសំណាក់ភាគីសហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តីរបស់លោក នួន ជា ជំទាស់ទៅនឹងសេចក្តីសម្រេចលើកទីពីរ នៃដីកាបំបែកសំណុំរឿងរបស់តុលាការដំបូង។[11] ការសម្រេចរបស់សាលាដំបូង ក្នុងការបំបែកសំណុំរឿងនៃករណី០០២ ទៅជា "សវនាការតូចៗ" ត្រូវបានលើកឡើងជាបញ្ហាសាជាថ្មីម្តងទៀត នៅក្នុងកិច្ចដំណើរការនីតិវិធីទាំងមូល។[12] សំណុំរឿងនាពេលបច្ចុប្បន្ន (ករណី០០២វគ្គទី១) ត្រូវបានកំហិតពិចារណាទៅលើបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលទាក់ទងទៅនឹងការជម្លៀសប្រជាជនដោយបង្ខំ (លើកទី១ និងលើកទី២) ដោយបន្ថែមពីលើការកាប់សម្លាប់ពីសំណាក់ទាហានខ្មែរក្រហម នៅឯទួលពោធិ៍ជ្រៃ។[13]

បណ្តឹងឧទ្ធរណ៍របស់ភាគីទាំងពីរបានលើកឡើងថា តុលាការដំបូងមិនបានបញ្ជាក់ឲ្យច្បាស់ពីបទនៃការចោទប្រកាន់ក្នុងករណី០០២វគ្គទី១ ហើយពួកគេបានស្នើសុំឲ្យតុលាការកំពូល ពង្រីកនូវវិសាលភាពសវនាការជំនុំជម្រះមួយនេះ។ ភាគីការិយាល័យសហព្រះរាជអាជ្ញា បានស្នើសុំឲ្យដាក់បញ្ចូលការចោទប្រកាន់ ពាក់ព័ន្ធទៅនឹងមន្ទីរស-២១ នៅពេលដែលមេធាវីការពារក្តីរបស់លោក នួន ជា បានដាក់សំណើថា "ការចោទប្រកាន់ដែលត្រឹមត្រូវ" គឺបានទាមទារឲ្យបញ្ចូលទាំងបទល្មើសប្រល័យពូជសាសន៍ និងតំណាងបទចោទប្រកាន់នៃឧក្រិដ្ឋកម្មនៅក្នុងសហករណ៍ និងកន្លែងការដ្ឋាននានា។

ទោះបីជាមានការបញ្ជាក់ថា ការបរាជ័យរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការដាក់បញ្ចូលវិសាលភាពនៃការចោទប្រកាន់ឲ្យកាន់តែច្បាស់លាស់បន្ថែមទៀត នៅក្នុងករណី០០២ វគ្គទី១ បានបង្កើតនូវកំហុសគតិយុត្ត និងកំហុសនៃការចេញសេចក្តីសម្រេចដោយប្រើប្រាស់នូវឆន្ទានុសិទ្ធក៏ដោយក៏អង្គជំនុំជម្រះតុលាការកំពូលបាន

យល់ឃើញថា ដីកាដំណោះស្រាយ "គឺមិនមែនមិនមានហេតុផល ដែលអាចទទួលយកបាន ដូចដីកាអន្តរាគមន៍ឧទ្ធរណ៍ឡើយ"។[14] ផ្ទុយទៅវិញ អង្គជំនុំជម្រះតុលាការកំពូល មិនបានធ្វើការផ្លាស់ប្តូរវិសាលភាពនៃសំណុំរឿង ០០២វគ្គទី១ នេះទេ ប៉ុន្តែបានបញ្ជាអង្គជំនុំជម្រះសាលាដំបូង ឲ្យធានាថា សំណុំរឿង០០២វគ្គទី២ នឹងមានបញ្ចូលឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ ស-២១ ការដ្ឋានមួយកន្លែង សហករណ៍មួយកន្លែង និងបទល្មើសប្រល័យពូជសាសន៍។ អង្គជំនុំជម្រះបានពិចារណាថា សំណើបែបនេះ គួរតែអាចប៉ះប៉ូវនូវបញ្ហានៃបទចោទប្រកាន់មិនគ្រប់គ្រាន់ ដែលបានពិភាក្សាដេញដោលកន្លងមក ហើយវាក៏ជាការចោទប្រកាន់ជារួមមួយ សម្រាប់ករណីទាំងពីរនេះ គឺករណី០០២ វគ្គទី១ និងករណី០០២ វគ្គទី២ ដែលនឹងត្រូវបានដាក់បញ្ចូលគ្នាទៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ជាកិច្ចគាំទ្រទៅនឹងការសម្រេចចិត្តរបស់អង្គជំនុំជម្រះខ្លួនឯង នៅក្នុងការសម្រេចមិនពង្រីកវិសាលភាពនៃសំណុំរឿង០០២ វគ្គទី១ សេចក្តីសម្រេចនោះបានបញ្ជាក់ពីការពន្យារ ទៅពេលខាងមុខបន្ថែមទៀត និងការព្រួយបារម្ភថា អង្គជំនុំជម្រះសាលាដំបូង "ប្រហែលជាមិនបានត្រៀមខ្លួនទុកជាមុន សម្រាប់ជំនុំជម្រះ" ពីបទឧក្រិដ្ឋដែលនៅសេសសល់នោះទេ។ លើសពីនេះទៅទៀត សេចក្តីសម្រេចនោះ បានណែនាំឲ្យការិយាល័យរដ្ឋបាល "ស្វែងរកឲ្យបានឆាប់រហ័ស" នូវអង្គជំនុំជម្រះមួយក្រុមទៀត ដើម្បីអាចចាប់ផ្តើមដំណើរការកាត់ក្តី ករណី០០២ វគ្គទី២ ឲ្យបានឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន បន្ទាប់ពីការបិទបញ្ចប់កិច្ចពិភាក្សាដេញដោល។ ការសម្រេចជាលាយលក្ខណ៍អក្សរយ៉ាងពេញលេញមួយ គឺត្រូវបានគេរំពឹងទុកថា នឹងត្រូវចេញ "យ៉ាងឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន"។

## ផ្នែកទី ៣៖ ការគ្រប់គ្រងសវនាការ

សប្តាហ៍នេះ កិច្ចដំណើរការនីតិវិធីបានប្រព្រឹត្តឡើង នៅថ្ងៃអង្គារ តែមួយថ្ងៃប៉ុណ្ណោះ។ កិច្ចប្រជុំពិភាក្សាពីការរៀបចំសវនាការ បានប្រព្រឹត្តទៅយ៉ាងរលូន បើទោះបីជាមានបញ្ហាលំបាកបន្តិចបន្តួច ពីការបកប្រែភាសាក៏ដោយ។ បន្ទាប់ពីបានស្តាប់ឮនូវអំណះអំណាងពីសំណាក់ភាគីទាំងអស់ អំពីបញ្ហាប្រឈមនានា ដែលនៅសេសសល់រួចមក អង្គជំនុំជម្រះបានប្រកាសផ្អាកសវនាការរយៈពេលបីម៉ោង ដើម្បីដំណើរការកិច្ចពិភាក្សា។ ក្រោយពីការត្រឡប់មកវិញរបស់អង្គជំនុំជម្រះ នៅម៉ោង ៣ រសៀល លោកប្រធាន **និល ណុន** បានប្រកាសនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ទៅលើបញ្ហាប្រឈមផ្សេងៗ និងការកំណត់កាលវិភាគចុងក្រោយ។

### ក. វត្តមាន

**វត្តមានជនជាប់ចោទ៖** លោក **នួន ជា** បានបន្តតាមដានកិច្ចដំណើរការនីតិវិធី ពីបន្ទប់ឃុំឃាំង ដែលស្ថិតនៅក្រោមបន្ទប់សវនាការ ដោយសារបញ្ហាសុខភាពរបស់គាត់ រីឯលោក **ខៀវ សំផន** វិញ គឺមានវត្តមាននៅក្នុងបន្ទប់សវនាការគ្រប់វគ្គទាំងអស់ នៃកិច្ចដំណើរការនីតិវិធី។

**វត្តមានដើមបណ្តឹងរដ្ឋប្បវេណី៖** មានវត្តមានដើមបណ្តឹងរដ្ឋប្បវេណីចំនួន ប្រាំបួននាក់ នៅក្នុងបន្ទប់សវនាការ និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣៨នាក់ផ្សេងទៀត បានមានវត្តមាននៅក្នុងសាលសវនាការសាធារណៈ។

**វត្តមានភាគី៖** ភាគីទាំងអស់ មានវត្តមាននៅក្នុងបន្ទប់សវនាការ ពេញមួយសប្តាហ៍។

**វត្តមានសាធារណជន**

| កាលបរិច្ឆេទ | ពេលព្រឹក | ពេលរសៀល |
|---|---|---|
| ថ្ងៃអង្គារ ២៣/០៧/១៣ | • សិស្សចំនួន ៣០០នាក់ និងប្រជាជនមកពីស្រុកប៉ុរីជលសា និងខេត្តតាកែវ<br>• ប្រជាជនចំនួន ៥០នាក់ មកពីស្រុកភ្នំស្រុក និងខេត្តបន្ទាយមានជ័យ<br>• អ្នកសង្កេតការណ៍បរទេសចំនួន ២៤នាក់ | • អ្នកសង្កេតការណ៍បរទេសចំនួន ៤នាក់ |

## ខ. ការគ្រប់គ្រងពេលវេលា

អង្គជំនុំជម្រះ ត្រូវបានសង្កេតឃើញថា បានគ្រប់គ្រងកិច្ចប្រជុំពិភាក្សាពីការគ្រប់គ្រងសវនាការសម្រាប់ករណី០០២ វគ្គទី១ បានយ៉ាងមានប្រសិទ្ធភាព ដោយបានស្តាប់អំណះអំណាងពីភាគីទាំងអស់ សម្រាប់រយៈពេលពីរវគ្គដំបូង ហើយបានចេញនូវសេចក្តីសម្រេច នៅពេលរសៀល បន្ទាប់ពីបានសម្រាកអស់រយៈពេលបីម៉ោង។ សម្រាប់រយៈពេល ២០នាទីចុងក្រោយ អង្គជំនុំជម្រះបានសម្រេចជូនដំណឹង ដល់ភាគីទាំងអស់ពីការសម្រេចរបស់អង្គជំនុំជម្រះ លើបញ្ហាដែលបានពិភាក្សា និងអះអាងពីកាលវិភាគចុងក្រោយ។

## គ. បញ្ហាបកប្រែ និងបច្ចេកទេស

នាសប្តាហ៍នេះ បញ្ហានៃការបកប្រែភាសា និងប្រព័ន្ធបំពងសំឡេង ក៏ត្រូវបានកត់សម្គាល់ឃើញថា បានកើតមានផងដែរ នៅក្នុងអំឡុងពេលនៃការចាប់ផ្តើមកិច្ចដំណើរការនីតិវិធី។ មានពេលជាច្រើននៅក្នុងថ្ងៃនោះដែលការបកប្រែបានពន្យារពេលភ្លាមៗ ខណៈដែលមេធាវីការពារក្តីលោក **គូប៉េ** និងលោកស្រី **អង់តា ហ្គីសសេ** លើកឡើងនូវបញ្ហា។

## ឃ. តារាងពេលវេលា

| កាលបរិច្ឆេទ | ពេលព្រឹកវគ្គ១ | ពេលព្រឹកវគ្គ២ | ពេលរសៀលវគ្គ១ | ពេលរសៀលវគ្គ២ | ចំនួនម៉ោងសរុប |
|---|---|---|---|---|---|
| ថ្ងៃអង្គារ ២៣/០៧/១៣ | ៩:០៦-១០:៣៤ | ១១:១១-១២:០០ | ១៥:០៧-១៥:២៤ | មិនមាន | ៥ម៉ោង និង ០១នាទី |
| *ចំនួនម៉ោងជាមធ្យមក្នុងសវនាការមួយវគ្គ៖* | | | *២ម៉ោងនិង៣៤នាទី* | | |
| *ចំនួនម៉ោងសរុបក្នុងសប្តាហ៍នេះ ៖* | | | *២ម៉ោង និង៣៤នាទី* | | |
| *ចំនួនសរុបនៃ ម៉ោង ថ្ងៃ និង សប្តាហ៍៖* | | | *៦៣៥ម៉ោង និង៥៦នាទី* | | |
| *រយៈពេលសវនាការចំនួន ២០៧ថ្ងៃ និង ៦៣សប្តាហ៍* | | | | | |

EAST-WEST CENTER

AIJI TRIAL MONITORING

WAR CRIMES STUDIES CENTER UNIVERSITY OF CALIFORNIA, BERKELEY

* AIJI is a collaborative project between the East-West Center, in Honolulu, and the War Crimes Studies Center,University of California, Berkeley. Since 2003, the two Centers have been collaborating on projects relating to theestablishment of justice initiatives and capacity-building programs in the human rights sector in South-East Asia.The Program is funded by the Open Society Foundation, the Foreign Commonwealth Office of the British Embassyin Phnom Penh, and the Embassy of Switzerland in Bangkok.

This issue of KRT TRIAL MONITOR was authored by Borany Bon, ChhayaChhin, Andrew Grant, PisethHuy,Melanie Hyde, SadafKashfi, Jessica Mawrence, John Reiss, Noyel Ry, KosalSor, SonanSorn, Lina Tay andPenelope Van Tuyl as part of AIJI's KRT Trial Monitoring and Community Outreach Program. KRT TRIAL MONITORReports on Case 002 are available at <www.krtmonitor.org>,and at the websites of the East-West Center and theWar Crimes Studies Center.

[1] The Trial Chamber has made an oral ruling on the matter on 18 April 2013, which it confirmed again on the 16 July 2013, that the Chamber would take alternation between silence and testimony into account when assessing the credibility of the Co-Accused, however would not determine guilt based solely on an adverse inference. SeeCASE 002 KRT TRIAL MONITOR, Issue 19, Hearing on Evidence Week 14 (18-20 April 2012).

[2] The Chamber did not officially close the evidentiary hearings due to the fact that the Supreme Court Chamber decision had not yet been released, but announced the scheduling of final deadlines. Parties are required to submit closing statement on 12 September 2013 in any one of court official languages (Khmer, English or French). Closing arguments will be heard on 9 October 2013 to 22 October 2013, including Fridays.

[3] The OCP was granted 225 pages, Defense teams: 125 pages, and CPLCLs: 105 pages for closing briefs.

[4] IR 35 states, "The ECCC may sanction or refer to the appropriate authorities, any person who knowingly and willfully interferes with the administration of justice, including any person who… b) without just excuse, fails to comply with an order to attend, or produce documents or other evidence before the Co-Investigating Judges orthe Chambers."

[5] President Nil Nonn told the Parties that the Chamber did not consider any new circumstances had arisen for Sar Sarin to be recalled, and that the requirements of Rule 35 therefore had not been met.

[6] IR 41.5 states, "At trial stage and beyond, Civil Parties may be summoned through the Civil Party Lead Co-Lawyers."

[7] IR 41.1 states, "A summons is an order to any person to appear before the ECCC. It may be issued to a Suspect, Charged Person or Accused, Civil Party or witness and shall set out the capacity in which the person is being summoned."

[8] IR 87.4 states, "Rules of Evidence. (4). During the trial, either on its own initiative or at the request of a party, the Chamber may summon or hear any person as a witness or admit any new evidence which it deems conducive to ascertaining the truth. Any party making such request shall do so by a reasoned submission. The Chamber will determine the merit of any such request in accordance with the criteria set out in Rule 87(3) above. The requesting party must also satisfy the Chamber that the requested testimony or evidence was not available before the opening of the trial."

[9] The Nuon Chea Defense made the request on 15 July 2013 in Court following the conclusion of Stephen Heder's testimony.

[10] **CASE 002 KRT TRIAL MONITOR. Issue 64. Hearing on Evidence Week 60. (17-20 June 2013).**

[11] For the Supreme Court Chamber's 23 July 2013 decision, see Supreme Court Chamber. "Decision on Immediate Appeals Against Trial Chamber's Second Decision on Severance of Case 002- A Summary of Reasons" (23 July 2013). E284/4/7. [hereinafter Decision on Immediate Appeals].

[12] For the Supreme Court Chamber's 8 February 2013 decision, see Supreme Court Chamber. "Decision on the Co-Prosecutors' Immediate Appeal of the Trial Chamber's Decision Concerning the Scope of Case 002/01" (8February 2013). E163/5/1/13. For KRT Monitor coverage, see CASE 002 KRT TRIAL MONITOR, Issue 39, Hearing on Evidence Week 34 (8-10 October 2012). For the Trial Chamber's 26 March 2013 oral decision, see CASE 002KRT TRIAL MONITOR, Issue 55, Hearing on Evidence Week 50 (25 & 29 March 2013).

[13] The Trial Chamber's Severance order dated 22 September 2011 lists the charges to be covered in Case002/01. The scope was subsequently expanded on 8 October 2012 to include both executions taking place in Kampong Tralach Leu District, and executions of former Lon Nol soldiers and officers at Tuol Po Chrey. Following an appeal from the OCP against the scope of charges in Case 002/01, the Supreme Court Chamber on 8February 2013 invalidated the Trial Chamber's initial severance decision. After having hearing the views of the Parties, the Trial Chamber issued a renewed severance decision on 29 March 2013, maintaining the same scope of the trial in Case 002/01 as it was before the Supreme Court Chamber's invalidation decision.

[14] Decision on Immediate Appeals. Paragraph 9, 3.